ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...[illegible]... សហវ.ហក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់ប្រាក់ឧបត្ថម្ភ ឆ្មប

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤.អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតំរូវការការងារចាំបាច់

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ថវិការដ្ឋ ក្នុងក្របខ័ណ្ឌនៃឥណទានថវិកា របស់ក្រសួងសុខាភិបាល ដើម្បីឧបត្ថម្ភដល់ឆ្មប ដែលបានជួយសំរាលកូន នៅតាមមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព សំដៅកាត់បន្ថយអត្រាមរណៈ មាតា និង ទារក អោយបានថយចុះ ជាអតិបរមា ។

-ទំ ២.-

ឧបត្ថម្ភថវិកា ជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់ នៅតាមមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ក្នុងទារក ០១ នាក់ ចំនួន ៦០.០០០ រ ( ហុកសិបពាន់រៀល ) ។

ឧបត្ថម្ភថវិកា ជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់ នៅតាមមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និងមន្ទីរពេទ្យបង្អែក ក្នុងទារក ០១ នាក់ ចំនួន ៤០.០០០ រ ( សែសិបពាន់រៀល ) ។

ប្រការ ៣.-

ការកំណត់លក្ខខណ្ឌផ្សេងៗ ក្នុងការឧបត្ថម្ភថវិកា ជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូន នៅតាមសេវាសាធារណៈ មានដូចខាងក្រោម :

- ចំពោះមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និងមន្ទីរពេទ្យបង្អែក ត្រូវមានឯកសារ ឬ លិខិតស្នាម ចុះហត្ថលេខា តាមឋានានុក្រម សំរេចយល់ព្រមដោយប្រធានអង្គភាព
- ចំពោះមណ្ឌលសុខភាព និង ប៉ុស្តិ៍សុខភាព ត្រូវមានឯកសារ ឬ លិខិតស្នាម ចុះហត្ថលេខា តាមឋានានុក្រម ដោយមានការឯកភាពពីប្រធានអង្គភាព និង មានការបញ្ជាក់ឯកភាពដោយក្រុមប្រឹក្សា ឃុំ-សង្កាត់
- ចំពោះទារក ដែលបានសំរាលរួចហើយ ហើយស្លាប់ក្នុងពេលសំរាល ឬ ក្នុងរយៈពេលសំរាកថែទាំក្នុងកន្លែងសំរាល មិនត្រូវរាប់បញ្ចូល ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភ នេះទេ ។

ប្រការ ៤.-

គំរូរបាយការណ៍ និង ឯកសារបច្ចេកទេស ព្រមទាំងលិខិតស្នាម ពាក់ព័ន្ធផ្សេងទៀតត្រូវរៀបចំ ដោយនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល ។

ប្រការ ៥.-

ការទូទាត់ប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុងប្រការ ២ ខាងលើនេះ ត្រូវធ្វើឡើងក្នុងមួយត្រីមាសម្តង ក្រោយពីមានរបាយការណ៍ និងឯកសារ ព្រមទាំង លិខិតស្នាម គ្រប់គ្រាន់ត្រឹមត្រូវច្បាស់លាស់ តាមនីតិវិធី ហិរញ្ញវត្ថុ ។

ប្រការ ៦.-

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព អង្គភាពពាក់ព័ន្ធទាំងអស់ ដែលស្ថិតនៅក្រោមឱវាទ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប៉ូ. ណុត_សុខុម

ចម្លងជូន :
-លេខាធិការដ្ឋានព្រឹទ្ធសភា
-លេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង រដ្ឋលេខាធិការដ្ឋាន
-សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
-ដូច
-ប្រការ ៦ "ដើម្បីអនុវត្ត"
-ឯកសារ និងកាលប្បវត្តិ

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ដើម្បីអនុវត្ត
ភ្នំពេញ ថ្ងៃទី១៨ ខែ០៤ ឆ្នាំ ២០០៧
អគ្គនាយក រដ្ឋបាល_ហិរញ្ញវត្ថុ

សាស្ត្រាចារ្យ កើត_មៀច